**BMI0085**

# សម្ភាសន៍ជាមួយឈ្មោះ លត ង៉ែត ភេទប្រុស អាយុ៦៣ឆ្នាំ
# មុខសញ្ញាជំនាន់ខ្មែរក្រហម«ប្រជាជនមូលដ្ឋាន»
# រស់ភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ
# ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០
# សម្ភាសន៍ដោយៈ សោម ប៊ុនថន
# ០០:៤៧:១៥
# ២១ទំព័រ

ប៊ុនថនៈ អ៊ំឈ្មោះអីដែរ?

ង៉ែតៈ ខ្ញុំឈ្មោះលត ង៉ែត ។

ប៊ុនថនៈ លត ង៉ែត?

ង៉ែតៈ បាទ ។

ប៊ុនថនៈ អ៊ំអាយុប៉ុន្មានហើយ?

ង៉ែតៈ ខ្ញុំអាយុ៦៣ហើយខ្ញុំ ។

ប៊ុនថនៈ អ៊ំមានស្រុកកំណើតនៅភូមិឃុំអីដែរ?

ង៉ែតៈ ខ្ញុំនៅភូមិផ្គាំ ឃុំផ្គាំនេះ ពីដើមស្រុកថ្មពួកឥឡូវស្រុកស្វាយចេកទីលំនៅសព្វថ្ងៃ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ នៅស្រុកស្វាយចេក ។

ប៊ុនថនៈ គេដូរ?

ង៉ែតៈ បាទ!គេដូរហើយ ស្រុកកំណើតខ្ញុំចុះហើយ កាលហ្នឹងថ្មពួក ខេត្តបាត់ដំបង ។

ប៊ុនថនៈ អ៊ំមានបងប្អូនប៉ុន្មាននាក់អ៊ំ?

ង៉ែតៈ ខ្ញុំមានបងប្អូន៦នាក់ ។

ប៊ុនថនៈ អ៊ំកូនទីប៉ុន្មាន?

ង៉ែតៈ ខ្ញុំទី៣ ។

ប៊ុនថនៈ ឪពុកម្តាយអ៊ំពីដើមគាត់ជាអ្នកធ្វើការដែរ?

ង៉ែតៈ អត់ទេ អត់មានធ្វើការអីទេ គាត់ជាអ្នកស្រែណាស់ ។

ប៊ុនថនៈ បាទ! ចឹងអ៊ំរៀនដល់ណាដែរ?

ង៉ែតៈ រៀនបានថ្នាក់ទី៧ «ចាស់» យើងពីដើម ។

ប៊ុនថនៈ ស្មើទីប៉ុន្មានឥឡូវអ៊ី?

ង៉ែតៈ មិនដឹងប៉ុន្មានទី៣ដឹង ។

ប៊ុនថនៈ ទី៧រាប់ពីលើចុះក្រោមវិញ?

ង៉ែតៈ ហ្នឹងហើយ ។

ប៊ុនថនៈ អ៊ីរៀននៅសាលាណាអ៊ី?

ង៉ែតៈ រៀននៅសាលាផ្គាំនេះ ។

ប៊ុនថនៈ ហ្នឹងកាលពីដំបូងអនុវិទ្យាល័យតែម្តងឬក៏?

ង៉ែតៈ ទេ ទើបកើតឆ្នាំ៩០ប៉ុន្មានទេ ខ្ញុំភ្លេចហើយ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ អនុវិទ្យាល័យទើបកើតទេ ពីដើមមានអនុវិទ្យាល័យនៅថ្មពួកនោះ ។

ប៊ុនថនៈ ចឹងពេលចប់នៅនេះបឋមហើយបានទៅថ្មពួក?

ង៉ែតៈ បាទ ។

ប៊ុនថនៈ ចឹងអ៊ីបានទៅរៀនដល់ថ្មពួកទេ?

ង៉ែតៈ អត់ទេ មិនបានរៀនទេចប់ត្រឹមថ្នាក់ទី៧ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ មិនបានទៅដល់ទេ រៀនបានតែអាប្អូនខ្ញុំទេបានវាទៅដល់ ។

ប៊ុនថនៈ កាលចប់ឆ្នាំណាអ៊ី?

ង៉ែតៈ ខ្ញុំចប់ឆ្នាំ៦៥ ។

ប៊ុនថនៈ ៦៥?

ង៉ែតៈ បាទ!១៩៦៥ ។

ប៊ុនថនៈ ចឹងយ៉ាងម៉េចបានជាអ៊ីឈប់កាលហ្នឹង?

ង៉ែតៈ វាគ្មានលុយគស្វ៊ូនិងគេទៅរៀនដល់នោះទៀតក៏វាខ្វះលុយខ្ញុំ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ កាលហ្នឹងក្រណាស់ពីដើម ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ឪពុកម្តាយក្រលំបាក ។

ប៊ុនថន៖ ចឹងបងប្អូនអ៊ំអីមានបានរៀនដូចអ៊ំទេ?

ងែត៖ រៀន រៀនទាំងអស់គ្នាបងប្អូនខ្ញុំ ។

ប៊ុនថន៖ បាទ ។

ងែត៖ បើបងស្រីខ្ញុំមិនបានរៀនទេ បើប្អូនៗ រៀនបានទាំងអស់គ្នា ។

ប៊ុនថន៖ បាទ ។

ងែត៖ សព្វថ្ងៃបានប្អូនធ្វើជាគ្រូចាត់តាំងនេះមករហូតទាំងអស់គ្នាបានបីនាក់ដែលទាំងខ្ញុំផងណា ។

ប៊ុនថន៖ បាទ ។

ងែត៖ តែខ្ញុំអាត្រែតហើយ ។

ប៊ុនថន៖ ចឹងក្រោយពីឈប់រៀនអ៊ំធ្វើអីទៀតអ៊ំ?

ងែត៖ ឈប់រៀនមានធ្វើអីខ្ញុំនៅផ្ទះដល់ពេលសម័យបីឆ្នាំហ្នឹងបំរើគេសម័យបីឆ្នាំហ្នឹងទៅ ។

ប៊ុនថន៖ បាទ ។

ងែត៖ មានធ្វើការអីនិងគេកាលសម័យបីឆ្នាំហ្នឹងធ្វើតែស្រែធ្វើតែចំការហ្នឹង គេឲ្យបរវទេះដឹកនេះដឹកនោះទៅណាចេះតែធ្វើតាមគេទៅ ។

ប៊ុនថន៖ បាទ!ចឹងអ៊ំនៅនេះសម័យរដ្ឋប្រហាហើយនៅឆ្នាំ៧០ហ្នឹងស្ថានភាពនៅក្នុងភូមិយ៉ាងម៉េចដែរពូ?

ងែត៖ អូស!នៅឆ្នាំ៧០យន្តហោះអាមេរិចកាំងអីណាទេ វាមកទម្លាក់ឆេះផ្ទះតិចណាស់ ឆេះរលាយអស់ កាលហ្នឹងខ្ញុំរត់ពីគេទៅ រត់អាពួកខ្មែរក្រហមនោះគេទៅវៃភូមិថ្កាំទៅនៅស្រុកកើតនេះ គេថាដីរំដោះខ្ញុំនោះគេចបាត់ទៅនៅខេត្តនោះជិតស្វាយស៊ីសាផុននោះ ។

ប៊ុនថន៖ បាទ ។

ងែត៖ ខ្ញុំទៅនៅនោះឯង នៅនោះយន្តទម្លាក់ខ្ទិចភូមិខ្ទិចអីអស់ ។

ប៊ុនថន៖ ចឹងនៅភូមិនេះអត់មានមនុស្សរស់នៅទេឬក៏មានដែរ?

ងែត៖ នៅនេះពីដើមនៅកូនផ្ទះពីរនាក់នៅចំការ ជាចំការទេ នេះទើបបង្កើតភូមិថ្មីតើ ។

ប៊ុនថន៖ ភូមិថ្កាំ?

ងែត៖ ទេ ភូមិថ្កាំអីណោះណា ថ្កាំភូមិធំណា ។

ប៊ុនថន៖ បាទ ។

ងែត៖ អានេះសព្វថ្ងៃដែលកើតជាភូមិនេះ គេមិនឲ្យជាភូមិណាដាក់ជាក្រុម ។

ប៊ុនថន៖ ជាក្រុម?

ង៉ែតៈ ជាក្រុមទី១ដាក់មួយក្រុមមានប្រជាជន៣០គ្រួសារប៉ុណ្ណោះឯង ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ មានអីច្រើន ដាក់ឈ្មោះផ្កាំៗតែនោះទេ ភូមិធំដែលមានបញ្ចាំផកុនឯកសារថ្ងៃមុននោះ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ អានេះជាក្រុមតើ ។

ប៊ុនថនៈ ចឹងអ្នកភូមិអី?

ង៉ែតៈ អានេះគេហៅភូមិគោកវែងចេះតែហៅភូមិទៅណា នៅជាក្រុមគេហៅភូមិគោគវែង ។

ប៊ុនថនៈ ចឹងកាលហ្នឹងខាងលន់ នល់មានមកដល់ហ្នឹងដែលអឹកាលឆ្នាំ៧០ហ្នឹង?

ង៉ែតៈ ៧០ហ្នឹង ។

ប៊ុនថនៈ បាទ!រដ្ឋប្រហាហ្នឹង?

ង៉ែតៈ លន់ នលមានមកតើ ។

ប៊ុនថនៈ មានមក?

ង៉ែតៈ បាទ ។

ប៊ុនថនៈ ចឹងអ្នកភូមិអីរស់នៅធម្មតារកស៊ីធ្វើការអី?

ង៉ែតៈ បាទ ។

ប៊ុនថនៈ ចឹងខ្មែរក្រហមចាប់មាននៅពេលណា?

ង៉ែតៈ ចូលបាននៅភូមិផ្កាំនៅ៩៣នេះ ។

ប៊ុនថនៈ តែចង់និយាយថាមុនរំដោះ៧៥នោះខ្មែរក្រហមមានចូលមកដែរ?

ង៉ែតៈ មានចូលមកខ្ញុំចាំឆ្នាំវាមិនបាន ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ វាមកម្ដងជាពីរដងបានវាវ៉ៃយកទាហានលន់ នល់នោះ វ៉ៃទាហានលន់ នល់នោះបានបែក ភូមិខ្ញុំបានរត់ពីនេះដូចខ្ញុំថា ខ្លះរត់ទៅក្រោមនោះខ្លះរត់ទៅនៅដីរំដោះទៅខ្មែរក្រហមណាស់ ។

ប៊ុនថនៈ ខ្មែរក្រហមគៀយកទៅៗ?

ង៉ែតៈ បាទ ។

ប៊ុនថនៈ ហើយអឹរត់ទៅស្វាយ?

ង៉ែតៈ ខ្ញុំរត់ទៅស្វាយ ។

ប៊ុនថនៈ អឹរត់ទៅនៅហ្នឹងយូរទេអឹ?

ង៉ែត: ខ្ញុំទៅនៅជិតមួយឆ្នាំហើយបានខ្មែរក្រហមរំដោះបាន បានមកចូលនិងគេមកថ្មពួក ថ្មពួកវ៉ៃអត់បានទេ ខ្ញុំមកនៅថ្មពួកដល់ពេលរំដោះថ្មពួកបាននេះ ។

ប៊ុនថន: បាទ ។

ង៉ែត: បានចូលមកតាមនេះ ចូលមកនៅក្នុងភូមិវិញ ។

ប៊ុនថន: បាទ ។

ង៉ែត: នៅភូមិកាលហ្នឹងគេប្រុងសម្លាប់ខ្ញុំដែរ តែខ្ញុំគេចវេសពីរបបគេនោះ ។

ប៊ុនថន: ចឹងកាលហ្នឹងមកទាំងប្អូនទាំងគ្រួសារ?

ង៉ែត: បាទ!ដល់មកវិញគេសុទ្ធតែជីវរំដោះ គេនិយាយសុទ្ធតែមិត្តៗអីគេទេ ថាតាមគេមិនត្រូវខ្ញុំចេះធ្វើតាមគេទៅគេប្រើចេះតែធ្វើទៅ ព្រោះខ្ញុំនៅខាងដី១៧មេសាណាស់ ។

ប៊ុនថន: បាទ ។

ង៉ែត: គេថាជីណាទេ ពួកអាលន់ នល់ទាហាន ។

ប៊ុនថន: បាទ ។

ង៉ែត: ខ្ញុំរត់គេចមកគេប្រើឲ្យធ្វើអីចេះតែធ្វើតាមគេទៅ កាលហ្នឹងគេសម្លាប់អ្នកដែលមកពីហ្នឹងឯងតែខ្ញុំអត់អីដែលបានរស់ទៅ ។

ប៊ុនថន: បាទ ។

ង៉ែត: ធ្វើតាមគេទៅ គេថាម៉េចចេះតែធ្វើតាមគេទៅ ។

ប៊ុនថន: ចឹងអ៊ំមកនៅពួកបានមួយរយៈ?

ង៉ែត: បាទ!មកនៅពួកមួយរយៈ ។

ប៊ុនថន: នៅហ្នឹងអ៊ំធ្វើអីដែរ កាលអ៊ំនៅពួកហ្នឹង?

ង៉ែត: អត់ទេ មានបានធ្វើអី ។

ប៊ុនថន: អត់ទេ និយាយធ្វើការរកស៊ីអី?

ង៉ែត: កាលនៅនោះវាមិនបានយូរទេ ទៅនៅបានតែប៉ុន្មានថ្ងៃគេរំដោះបានចូលមកភូមិកាលនោះមានទាន់រកអីអន្ទូរដឹកទៅស៊ីខ្លួនឯង ចេះតែទិញនេះទិញនោះគេ ។

ប៊ុនថន: ចឹងមកដល់ភូមិហ្នឹងប្រជាជនដែលជម្លៀសទៅហ្នឹងចូលមករស់នៅក្នុងភូមិហ្នឹងវិញដែរ?

ង៉ែត: បាទ!មកពីជីវរំដោះវិញ អ្នកដែលនៅខាងដី១៧មេសានោះចូលមកនៅផ្ទះវិញ គេឲ្យមកនៅតាមស្រុកតាមស្រែវិញ មកនៅក្រោមអំណាចប៉ុល ពតនេះ ។

ប៊ុនថន: បាទ!ចូលមកប្រធានភូមិប្រធានឃុំគេរៀបចំយ៉ាងម៉េចដែរ នៅក្នុងភូមិហ្នឹង?

ង៉ែតៈ គេរៀបចំសុទ្ធតែគេពីក្នុងមកណាស់ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ស្អីគេហៅថា... សុទ្ធតែគេរៀបមកពីនោះមានប្រធានសហករណ៍មានអីប្រធានស្អីណាទេ សុទ្ធថ្នាក់គេមកពីនោះនិយាយទៅអត់មានណាធ្វើអីទេ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ហ្នឹងមានអីសុទ្ធតែគេមកពីក្នុងមកពីនិរតីគេហៅនិរតីណាស់ គេហៅពួកនិរតីគេមកពីនោះ ហើយមានកាន់ភូមិមានអីហ្នឹង ។

ប៊ុនថនៈ បាន ។

ង៉ែតៈ កាលហ្នឹងគេដាក់ជាសហករណ៍ៗចឹងទៅ ។

ប៊ុនថនៈ ចឹងអ៊ីគេចាត់តាំងឲ្យធ្វើអីដែលកាលហ្នឹង?

ង៉ែតៈ ខ្ញុំអត់មានធ្វើអីទេ ដល់ឆ្នាំ៧៧ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ឆ្នាំ១៩៧៧ ខ្ញុំទៅធ្វើលូជីកថ្មគេ ធ្វើលូនេះត្រពាំង តា ម៉េងនេះ ។

ប៊ុនថនៈ គេហៅអាងអីវិញអ៊ី?

ង៉ែតៈ គេហៅអាងតា ម៉េង ។

ប៊ុនថនៈ អាងតា ម៉េងហ្នឹងធំទេ?

ង៉ែតៈ ធំ សព្វថ្ងៃគេលើកធំទៀតនៅជីកថ្មឲ្យគេទៅដល់ពេលខែប្រូតកាត់ចេះគោខ្ញុំមានក៏ចេះតែជីក ជួនណាទៅជីកអង្គរគេឲ្យទៅជីកនៅថ្មពួកជីកយកមកឲ្យប្រជាជនប្រូតកាត់ស៊ីបបរណា ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ កាលនោះនិយាយមិនបានទេ វេទនាណាស់ ។

ប៊ុនថនៈ ចឹងកាលរំដោះភ្លាមរបបហូបចុកយ៉ាងម៉េចដែរ?

ង៉ែតៈ កាលចាប់ពីឆ្នាំ១៩៦០ប៉ុន្មានទេ ៧៦ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ឆ្នាំ១៩៧៦ ឆ្នាំនេះកម្មមែនទែនហើយកាលនោះស៊ីបាយតាមក្រុមមួយកំប៉ុងគ្នា១០នាក់ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ភាវៗទេ កាលនោះវេទនាណាស់ ។

ប៊ុនថនៈ ចឹងមុនហ្នឹងអាចដាំបាយហូបនៅផ្ទះអីបាន ចាប់ពី៧៦ទៅចាប់ផ្តើមហូបរួមហើយ?

ង៉ែត: បាទ!មុនដាំបាយស៊ីតាមផ្ទះបានធ្វើស្រែឆ្នាំនោះបានច្រើនណាស់ ។

ប៊ុនថន: បាទ ។

ង៉ែត: កាលនោះកើតមហាកើតដាក់ដល់នេះគេយកទៅដាកលតាមជង្រុកធំៗ ប្រមូលដាក់ទាំងអស់ ពេញៗអស់ស្រូវនៅភូមិផ្តាំ ។

ប៊ុនថន: ធ្វើបានផលច្រើន?

ង៉ែត: បាទ!ធ្វើបានស្រូវច្រើនណាស់ឆ្នាំនោះ ដល់ហើយគេថាដឹកយកទៅឲ្យប្រទេសចិនអីណាទេ យកទៅដូរស្អីទេ ដឹកៗទៅដល់ឆ្នាំ១៩៧៦នេះហើយ ចូលម្ទូតតាមជង្រុករលីងតាំងបបរ បណ្តោយ ។

ប៊ុនថន: បាទ ។

ង៉ែត: ឲ្យអង្គរគ្នាបបរតាមក្រុមចាប់ផ្តើមក្រុមហ្នឹងហើយ ។

ប៊ុនថន: ចឹងអ៊ំនៅខាងក្រុមធ្វើស្រែដែរ?

ង៉ែត: បាទ!នៅក្រុមធ្វើស្រែ ។

ប៊ុនថន: ចឹងកាលអ៊ំនៅខាងដឹកថ្មហ្នឹងយូរដែលទេ?

ង៉ែត: នៅមួយឆ្នាំដែរ ។

ប៊ុនថន: ចឹងនៅធ្វើការដ្ឋានហ្នឹងដល់ហើយតែម្តងបានឈប់?

ង៉ែត: បាទ!ដល់ហើយឆ្នាំ៧៧ហ្នឹងជិតហើយទៅហើយខ្ញុំចូល៧៨ហើយបានហើយ ។

ប៊ុនថន: តែប្រើប្រាស់បានទេអ៊ំ?

ង៉ែត: ប្រើប្រាស់បានម៉ានេះដែរ ខ្ញុំធ្វើតែលូសុទ្ធតែជាងគេផ្សេងទេ ខ្ញុំគ្រាន់តែដឹកតែថ្មឲ្យគេ ។

ប៊ុនថន: បាទ!មានបណ្តោយប៉ុន្មានទទឹងប៉ុន្មានដែរអាងហ្នឹង?

ង៉ែត: អាងហ្នឹងវាតូច ធ្វើមុនដំបូងតូចនោះ កាលសម័យបីឆ្នាំនោះធ្វើតូចដល់សម័យនេះគេធ្វើធំ ណាស់សព្វថ្ងៃហ្នឹង ធ្វើធំហើយនៅតែបាក់ទៀត ។

ប៊ុនថន: ចឹងអាងហ្នឹងនៅក្នុងភូមិឃុំអីដែរ?

ង៉ែត: សព្វថ្ងៃនៅក្នុងឃុំគោកកថិន ។

ប៊ុនថន: ចឹងពីមុន?

ង៉ែត: ពីមុននៅក្នុងភូមិផ្តាំ ឃុំផ្តាំ កាលនោះប្រជាជនច្រើនណាស់ ។

ប៊ុនថន: បាទ ។

ង៉ែត: តែនៅជុំវិញតែឃុំផ្តាំមួយ តែឥឡូវគេបំបែកឃើងសព្វថ្ងៃណាស់ ។

ប៊ុនថន:	បាទ ។

ង៉ែត:	សម័យហេង សំរិនយើងនេះ សព្វថ្ងៃនេះកាត់ភូមិទៀសនេះមួយ មើលទៅច្រើនពេកកាត់ឥឡូវដាក់ថា គោកកបិន ។

ប៊ុនថន:	ចឹងអ៊ំធ្វើនៅហ្នឹងហើយអ៊ំមកខាងដឹកស្រូវវិញ?

ង៉ែត:	បាទ!ខ្ញុំនៅខាងដឹកស្រូវមកឲ្យគេកិនគេយកតាំងពីដើងគ្រោះតាំងពីណា ។

ប៊ុនថន:	កាលហ្នឹងស្រូវច្រើនទេ អ៊ំកាលហ្នឹង?

ង៉ែត:	ទៅដឹកមួយបាវពីរបាវមកយកឲ្យប្រធានសហករណ៍គេចាត់ចែងឲ្យទៅកិនអង្ករគិនអីទៅគេចែកទៅតាមក្រុមទៅណាស់ ។

ប៊ុនថន:	បាទ ។

ង៉ែត:	សហករណ៍គេកិនបានទៅចែកតាមក្រុមឲ្យបបរណាស់ ។

ប៊ុនថន:	ចឹងអ៊ំនៅខាងដឹកជញ្ជូនអង្ករហ្នឹងរហូតប្តូមួយក៏មួយក៏ដូរទៅខាងណាវិញ?

ង៉ែត:	រហូតដល់ឆ្នាំ៧៩ហ្នឹងគេរំដោះដុតមក មកក៏បានដុតទៅ ។

ប៊ុនថន:	បាទ!ចឹងនៅពេលរំដោះ៧៩ហើយអ៊ំទៅណាទៀត?

ង៉ែត:	៧៩នៅភូមិនេះហើយ ។

ប៊ុនថន:	និយាយថាអត់មានជម្លៀសរត់ទៅខាងណាទៀតទេ?

ង៉ែត:	អត់ទេ អត់មានរត់ទៅណាទេ ។

ប៊ុនថន:	បាទ ។

ង៉ែត:	នៅតែភូមិផ្កាំហ្នឹងឯង ។

ប៊ុនថន:	ចឹងវៀតណាមចូលមកដល់ទេអ៊ំ?

ង៉ែត:	សម័យវៀតណាមនោះ ។

ប៊ុនថន:	ហ្នឹងហើយ ។

ង៉ែត:	វៀតណាមចូលមកនៅពេញតែប្រទេសហ្នឹងហើយ មើលកាលសម័យប្រជាជនវៀតណាមមិនទាន់មកដល់នេះទេ នៅតែស្វាយស៊ីសាផុនយើងនោះ ដល់ពេលនេះខ្មែរក្រហមវាទាញជីវិតខ្ញុំទៅនៅថ្នល់ដាច់នោះ ដល់ទៅនៅថ្នល់ដាច់ទៅមានពួកប៉ារាចុះមក ។

ប៊ុនថន:	បាទ ។

ង៉ែត:	ហើយឲ្យពួកខ្ញុំនេះដើរយកស្រូវតាមនេះដឹក ដឹកស្រូវតាមជង្រុកគេដែលផ្អើលភ្ញាក់ចេះណាស់ ។

ប៊ុនថន: បាទ ។

ង៉ែត: ពួកខ្មែរក្រហមផ្អើល ពួកខ្មែរក្រហមពួកប៉ាវាអីទៅវារត់ចោលទៅ ទៅដឹកអាស្រូវហ្នឹងយកមកទុកល្អាងតា ម៉េងនេះឯង ។

ប៊ុនថន: បាទ ។

ង៉ែត: ដល់ធ្វើជម្រុកធ្វើអីបានទៅដឹក ដឹកយកមកដាក់នៅនេះដេញឯងឲ្យទៅនោះវិញ ទៅនៅអីថ្នល់ដាច់ ។

ប៊ុនថន: បាទ ។

ង៉ែត: ដល់ទៅនៅថ្នល់ដាច់វៀតណាមឡើងវៃពីនេះមក ដល់នេះវាផ្អើលវា វាឲ្យមកនៅតា ម៉េងវិញ ។

ប៊ុនថន: បាទ ។

ង៉ែត: ឲ្យមកនៅតា ម៉េងខ្លាចវៀតណាមឡើងដល់ហ្នឹង ដល់មកនៅតា ម៉េងប៉ះប៉ាវា ប៉ាវាវាចូលមកដែរ វាចូលមករំដោះដែលប៉ាវា ដល់ចូលមកប៉ាវាទប់ទល់ទៅបានខ្មែរក្រហមផ្សេងកាលហ្នឹងខ្មែរក្រហមនិងប៉ាវាមានត្រូវគ្នាណា ។

ប៊ុនថន: បាទ ។

ង៉ែត: ដល់នេះទៅខ្ញុំគេចមកនៅតា ម៉េងនេះ តែថាវៀតណាមចូលមកដល់ថ្នួកវិញ ចូលពីតាមថ្នល់មកចូលថ្នួលពួក ។

ប៊ុនថន: បាទ ។

ង៉ែត: ដល់ថ្នល់ពួកគេហៅចាស់ទុំឲ្យមកជួបគេ ដល់មកជួបគេ គេថាឲ្យមកចូលស្រុកវិញវៀតណាមដល់ឲ្យចូលស្រុកវិញក៏នាំគ្នាបរទេសចូលស្រុកគគ្រឹកទៅខ្ញុំបរកាត់ត្រង់នោះចូលពីល្អាងតា ម៉េងមកចេះមក មកដល់ផ្ទះវៀតណាមនៅឲ្យពេញផ្ទះអស់ មានដល់វៀតណាមមកគ្រេវគ្រោដនិងវៀតណាមទៅក៏នៅមិនបានយូរដេញខ្មែរក្រហមកាលសម័យហ្នឹង ។

ប៊ុនថន: បាទ ។

ង៉ែត: ដល់នេះទៅនៅបានមួយយប់ ដេញវៀតណាមធ្លាក់ដល់បេងពោធិខាងនោះ ។

ប៊ុនថន: ខាងណាដេញអ៊ី?

ង៉ែត: យួនវាដេញ ។

ប៊ុនថន: ដេញប្រជាជនហ្នឹង?

ង៉ែត: អត់ទេ ដេញខ្មែរក្រហម ។

ប៊ុនថនៈ ដេញខ្មែរក្រហម?

ង៉ែតៈ ហ្នឹងហើយ ខ្មែរក្រហមគ្នារត់បាស់ដៃបាស់ជើងខ្លះឆ្លងទៅនៅស្រុកថៃអស់ ។

ប៊ុនថនៈ ចឹងអ៊ឹចូលមកនៅខាងប៉ារា?

ង៉ែតៈ អត់ទេ ខ្ញុំនៅឆ្នាំនេះឯង ដូចថានៅជីរំដោះណាប៉ារាផងខ្មែរក្រហមផង ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ខ្មែរក្រហមក៏នៅប៉ារាក៏នៅចេះ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ភូមិឆ្នាំនេះនៅឯកោមានពីណាត្រួតត្រា ខាងទាហានយើងនិងនៅខាងតែថ្មពួក ស្វាយស៊ីសាផុននោះ ។

ប៊ុនថនៈ និយាយថាខាងខ្មែរក្រហមខាងប៉ារាខាងវៀតណាមចូលមកចឹងមានសួរអីប្រជាជនទេអ៊ឹមានធ្វើបាបឬមានអីទេ?

ង៉ែតៈ អានោះវាមានដែល តែខាងវៀតណាមមុនដំបូងល្អ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ វៀតណាមចូលមុនដំបូងល្អណាស់វា ដល់ខ្មែរយើងទំលាប់ចេះលួចចេះឆក់វាក៏ធ្វើតាមទៅ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ មុនដំបូងសូម្បីតែបន្លែផ្លែឈើដាំនៅពេញភូមិចឹង អត់ហ៊ានទេទាល់តែសួរទាល់តែសុំ ដូនសុំដូរជាអង្ករ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ដល់យូរៗទៅទាហានខ្មែរយើងចេះប្រឡំខូចទៅបានវាធ្វើតាមទៅ ពួកខ្មែរក្រហមមិនដំបូងចូលធ្វើបាបដែរ សូម្បីប្រជាជនយើងដែលនៅក្នុងភូមិមានស្បែកជើងកង់ឡាន ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ វាចង់បាញ់ឯងមានសព្វគ្រប់ហើយ វាថាឯងទៅលួចរបស់វា ឲ្យតែវាឃើញមានស្បែកជើងដូចវា ស្រេចតែវាថា បើខ្ញុំផងពិបាកជាងគេណាស់ខ្ញុំ វេទនាណាស់ និយាយក្នុងភូមិឆ្នាំមួយនិយាយថាកាត់មួយកំណាត់ខាងជើងពាក់កណ្តាលសាលាបឋមមកជើងចេះ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ មនុស្សរត់ខាងទាហានខាងក្នុងនោះមកក៏ធ្វើបាប ចោទពីណាពីណើវាយកគ្រាប់បែកមកពីណាទេ មកចោទខ្ញុំថា ខ្ញុំណាមានគ្រាប់បែកនៅក្នុងផ្ទះ ។

ប៊ុនថន: បាទ ។

ងែត: តែខ្ញុំវាមិនអីចេះតែរួចទៅ ខ្ញុំសម្ដែងការស្មោះត្រង់ហើយ ខ្ញុំត្រង់ក៏មិនអីទៅ ។

ប៊ុនថន: ចឹងមានចាប់មានអីទេ មានចាប់ប្រជាជនមានអីទេ?

ងែត: អត់ទេ អត់មានចាប់ទេ ។

ប៊ុនថន: គ្រាន់តែគំរាមអីទេ?

ងែត: បាទ!គំរាមបាញ់ទាបាញ់មាន់ចឹងទៅដែរ ។

ប៊ុនថន: ចឹងអ៊ំនៅហ្នឹងដូចជានៅកណ្ដាលចឹង មានអ្នកគ្រប់គ្រងច្រើនអីចឹង?

ងែត: បាទ ។

ប៊ុនថន: ចឹងមានវ៉ៃគ្នាទេ នៅក្នុងភូមិហ្នឹង?

ងែត: វ៉ៃគ្នាវៀតណាមជាមួយខ្មែរក្រហម ។

ប៊ុនថន: បាទ!ខាងប៉ុលពតខាងអីចឹង?

ងែត: មានវ៉ៃរាល់ខែរាល់ឆ្នាំមានវ៉ៃទំពាំរំដោះបានវ៉ៃដល់ហើយ ទើបដល់បោះឆ្នោតរួចនេះបាន គ្រាន់ បានដល់៩៣នេះបានគ្រាន់ពីនោះមកវ៉ៃ វ៉ៃត្រង់នេះវ៉ៃត្រង់នោះ ។

ប៊ុនថន: បាទ!ខាងខ្មែរក្រហមពីណាជាអ្នកគ្រប់គ្រង?

ងែត: កាលនោះវៀតណាម ។

ប៊ុនថន: បាទ ។

ងែត: វៀតណាមនៅឈរជើងនៅផ្កាំហ្នឹង ។

ប៊ុនថន: តែដូចថាខាងខ្មែរក្រហមដូចថាបក្ស?

ងែត: ខ្មែរក្រហមលួចឆ្មក់បាញ់ណាស់ បាញ់ថ្ងៃណាបាញ់ទទេវាមិនមានវៀតណាមទេ ផាប់តែខ្លួនវា ។

ប៊ុនថន: បាទ!ចុះខាងប៉ុលពត?

ងែត: ប៉ុលពតមិនសូវទេ កាលហ្នឹងដល់សម័យក្រោយៗមកបានខ្មែរក្រហមបាញ់បានរំដោះបានខ្លះទៅបានមានកំលាំងមាំមួនទៅចូលវ៉ៃទីក្រុងធំៗដូចជាថ្មពួកអី ។

ប៊ុនថន: បាទ ។

ងែត: ដូចជាស្វាយចេកអីហ្នឹង ។

ប៊ុនថន: បាទ ។

ង៉ែតៈ ថ្មលពួកនេះបានវាជួយកំលាំងគ្នា កាលមុនប៉ុរាភតែវាផ្សេងទៅ ដល់នេះទៅបានត្រូវគ្នា ត្រូវគ្នាបានមកផ្តុំគ្នាមកវៃមែនទែន រំដោះបានដីស្មាយចេកអីហ្នឹង ។

ប៊ុនថនៈ ចឹងខាងប៉ុរាភត្រូវជាមួយខាងខ្មែរក្រហម?

ង៉ែតៈ ហ្នឹងហើយមិនដឹងជារឿងគេយ៉ាងម៉េចនោះ សព្វថ្ងៃបង្កើតប៉ុរាភដើម្បីជួយវៃខ្មែរក្រហម កាលនេះរត់ទៅធ្វើប៉ុរាភបំណងដែលខឹងៗខ្មែរក្រហម ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ កាលហ្នឹងខឹងខ្មែរក្រហមដល់ទៅត្រូវគ្នានិងខ្មែរក្រហម ។

ប៊ុនថនៈ ចឹងអ្នកភូមិចូលធ្វើប៉ុរាភច្រើនទេអ៊ី?

ង៉ែតៈ មានប៉ុរាភមានច្រើនគ្រាន់ដែរ ខ្មែរក្រហមច្រើនដែលនៅឆ្នាំនេះ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ខ្មែរក្រហមច្រើន ។

ប៊ុនថនៈ ចឹងខ្មែរក្រហមទៅច្រើនដែលភូមិហ្នឹងអ៊ី?

ង៉ែតៈ ច្រើន ដល់ធ្វើសមាហរណ៍កម្មទៅក៏បានត្រឡប់មកវិញមក ។

ប៊ុនថនៈ ចឹងអ៊ីនៅនេះរហូតកាលឆ្នាំ៧៩ហើយហ្នឹង ។

ង៉ែតៈ បាទ! នៅហ្នឹងរហូត ។

ប៊ុនថនៈ ចឹងប៉ុរាភអីអស់នៅឆ្នាំណាអ៊ី?

ង៉ែតៈ ប៉ុរាភវាចប់តែដំណាលគ្នាហ្នឹងហើយ ចប់ដំណាលគ្នានៅពេលបោះឆ្នោតអី ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ចប់ទៅមិនដឹងជាបែកក្រុមទៅណាទេ ខ្ញុំមិនដឹងដែរ ។

ប៊ុនថនៈ ចឹងនៅពេលបោះឆ្នោតហើយភូមិនេះយ៉ាងម៉េចដែលអ៊ីស្គាលភាពអីចឹងមានសន្តិសុខឬនៅ?

ង៉ែតៈ បោះឆ្នោតហើយនៅតែមានដែរ ។

ប៊ុនថនៈ មានយ៉ាងម៉េចវិញ?

ង៉ែតៈ បោះឆ្នោតហើយនោះពួកខ្មែរក្រហមវៃប៉ុរាភវៃទាហានយើងខាងក្នុងនេះណាស់ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ នៅវៃតែចុះវាមិនទាន់ចប់ណាស់ ដល់ស្ងាត់នៅឆ្នាំ៩៦-៩៧ហ្នឹងដឹង ។

ប៊ុនថនៈ ចឹងអ៊ីចូលធ្វើការនៅឆ្នាំណាវិញ?

ង៉ែតៈ ធ្វើការខាងគ្រូនោះ ។

ប៉ុនថន: បាទ ។

ង៉ែត: ខ្ញុំចូលឆ្នាំ៨២ ។

ប៉ុនថន: ៨២?

ង៉ែត: បាទ ។

ប៉ុនថន: ចឹងអ៊ីដំបូងធ្វើអីវិញ?

ង៉ែត: មុនដំបូងឆ្នាំ៧៩មក៨០ កាលវៀតណាមចូលមកខ្ញុំមិនប្រធានគេទេ ខ្ញុំធ្វើឃុំធ្វើមេឃុំ ។

ប៉ុនថន: បាទ ។

ង៉ែត: ព្រោះខ្ញុំធ្វើវេគេ ដល់ឆ្នាំ៨២ខ្ញុំចេញពីឃុំមកនៅមើលទៅពិបាកពេកវៀតណាមវាគ្រប់គ្រងស្អីៗនៅលើវា ។

ប៉ុនថន: បាទ ។

ង៉ែត: ធ្វើបាបខ្ញុំណាស់ ខ្ញុំគេច ។

ប៉ុនថន: ធ្វើបាបយ៉ាងម៉េចវិញអ៊ី?

ង៉ែត: វាធ្វើបាបវាសម្គុតវាប្រើឯងធ្វើមិនទាន់ជំនាញការនោះវាសម្គុតឯងវាយកកាំភ្លើងមកភ្ជង់ ។

ប៉ុនថន: កាលហ្នឹងនៅឃុំអីវិញ ឃុំផ្គាំយើងនេះ?

ង៉ែត: ឃុំផ្គាំយើងហ្នឹង ។

ប៉ុនថន: ចឹងអ៊ីចេញពីហ្នឹងមកខ្ញុំចូលធ្វើការអីវិញ?

ង៉ែត: ជាលោកគ្រូបង្រៀនគ្រូចាត់តាំងទៅរៀនបានបីខែនៅបាត់ដំបងទៅបានធ្វើការជាប់មកដល់ឆ្នាំ២០០៧បានខ្ញុំអាត្រែត ។

ប៉ុនថន: បាទ ។

ង៉ែត: បាន២៣ឆ្នាំ ។

ប៉ុនថន: កាលចេញដំបូងបង្រៀននៅណាវិញអ៊ី?

ង៉ែត: មានបង្រៀននៅណាទេ ខ្ញុំបង្រៀននៅតែផ្គាំហ្នឹង បង្រៀននៅផ្គាំរបូត ។

ប៉ុនថន: បាទ!បង្រៀននៅហ្នឹងតែបឋមសិក្សាទេអ៊ី?

ង៉ែត: បាទ!បឋមសិក្សាអនុវិទ្យាល័យទើបតែបង្កើតនេះឯង នេះអាសាលាកណ្តាលហ្នឹងផ្គាំ ។

ប៉ុនថន: បាទ!ចឹងអ៊ីបង្រៀននៅកណ្តាលទេ?

ង៉ែត: បាទៗ!បង្រៀននៅកណ្តាលហ្នឹង ។

ប៉ុនថន: ចឹងអ៊ីនៅនេះ កាលអ៊ីធ្វើជាប្រធានឃុំហ្នឹងពិបាកដែរមានបីភាគីចឹង?

ង៉ែតៈ ពិបាក ។

ប៊ុនថនៈ ពិបាកយ៉ាងម៉េចវិញអ៊ំអាចរៀបរាប់បានទេ?

ង៉ែតៈ ពិបាកណាស់ធ្វើការជាមួយពីណាគ្រាន់បើ ណាមួយខាងព្រៃវាមកទាក់ទងសុំអង្ករ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ទាក់ទងសុំអង្ករដល់ហើយ យើងកាលណាត្រូវតែវែងមិនបែកចែកវែកខ្លះវាធ្វើបាបវាបាញ់ផ្លោងទម្លាក់មកតាមភូមិ បាញ់ទាំងវៀតណាមបាញ់ទាំងយើងដល់ហើយគ្រោះថ្នាក់ដល់យើង ។

ប៊ុនថនៈ ខាងខ្មែរក្រហមហ្នឹង?

ង៉ែតៈ ហ្នឹងហើយ បើមិនត្រូវជើងវាមានទៅម៉ែឳទេ ។

ប៊ុនថនៈ ចឹងខាងប៉ុរាមានដែលមកសុំអង្ករអីទេ?

ង៉ែតៈ ប៉ុរាក៏សុំ សុំអង្ករសុំអី សុំទៅក៏លួចរំដោះទៅណាស់ ឲ្យទៅណាស់ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ធ្វើឲ្យវៀតណាមហ្នឹងទាស់ យើងធ្វើម៉េចឲ្យចេះចែកគ្នាស៊ីទៅកុំឲ្យវាទាស់ទែញជាមួយប្រជាជនណាស់ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ទាស់ជាមួយវៀតណាមវាមិនមែនទាស់តែវៀតណាមទេ វាទាស់ជាមួយប្រជាជនម្នោះហើយត្រូវតែវែកពន្ធខ្លះទៅ ។

ប៊ុនថនៈ ចឹងអ៊ំបង្រៀននៅនេះមានស្គាល់តា ពិនអីទេ?

ង៉ែតៈ តា ពិននោះមកនៅឆ្នាំមកនៅឆ្នាំ៩៣អីនេះអី ខ្ញុំវាភ្លេចដងសព្វថ្ងៃវាចាស់ចង់វង្វេង ។

ប៊ុនថនៈ កាលគាត់មកបោះឆ្នោះហើយនៅ?

ង៉ែតៈ បោះឆ្នោតហើយ ដល់មកនៅនេះចាប់ផ្ដើមនៅធ្វើដូចថាវាគាត់នោះវាមកពីខ្សែខ្មែរក្រហមខ្មែរក្រហមគេមានម៉ាស៊ីនកិនស្រូវអីណាស់ មកដាក់នៅភូមិខាងជើងនេះ ត្រូវគ្នាជាមួយពួកខ្ញុំហ្នឹងឯង មើលឃើញត្រូវគាត់វាចេះច្រើន គាត់ប្រាប់ពីប្រវត្តិគាត់ថាជាសាស្ត្រាចារ្យគាត់ថាជាគ្រូសាស្ត្រាចារ្យដល់នេះឃើញគាត់ចេះច្រើនគាត់មិនមានការងារធ្វើពួកខ្ញុំនេះហើយឲ្យគាត់ចូលជាគ្រូបង្រៀន ឲ្យចូលគ្រូបង្រៀនឲ្យទៅបង្រៀននៅអនុវិទ្យាល័យ ។

ប៊ុនថនៈ បាទ ។

ងើត: បង្រៀនអនុវិទ្យាល័យទៅដល់ពេលទៅខ្ញុំឆ្នាំ៩៦ឆ្នាំ១៩៩៦ខ្ញុំកើតខ្វិន ឈឺពោះក៏ថតមើល នៅពេទ្យមន្ទីលបូរីគេថាខ្វិនគ្រាប់ ដល់ខ្វិនគ្រាប់គេវះ ដល់គេវះខ្ញុំទៅនៅដេកវះទៅឆ្នាំនោះ មានចោរប្លន់តា ពិននេះ ថាមាសទាំងកំប៉ុងៗ ប្លន់តា ពិនស្លាប់យាយម៉ៅប្រពន្ធតា ពិន ហ្នឹងណាស់ ។

ប៊ុនថន: បាទ ។

ងើត: ស្លាប់ទៅខ្ញុំនៅតែអីនោះ នៅតែមន្ទីលបូរីនៅខេត្តនោះដល់ពេលត្រឡប់មកវិញមើលទៅ សភាពការណ៍ មិនស្រួលតិចទាហានខាងក្នុងណាស់ ទាហានខាងក្នុងឲ្យចាប់តា ពិនអានោះខ្ញុំ មកហើយ ខ្ញុំមកផ្ទះមកពីពេទ្យហើយជា ។

ប៊ុនថន: បាទ ។

ងើត: ខ្ញុំចេះតែមិនបានដឹងរឿង មិនដឹងរឿងក៏ស្រណោះគាត់មិនដឹងថាប្រវត្តិគាត់ធ្វើអីៗ ទេ ។

ប៊ុនថន: បាទ ។

ងើត: មិនបានដឹងទេ ស្រណោះគាត់ក៏ធានាគាត់លោកនៅសព្វថ្ងៃនេះ ធានាខាងប៉ារាំនោះណាស់ ធានាទៅក៏បានរួចទៅ រួចខ្វិនមួយវគ្គគេមិនធ្វើបាបទេ គេបញ្ជាមកពីថ្នាក់លើពីបញ្ជាពីថ្មពួក ហ្នឹងគេឲ្យចាប់តា ពិនយកទៅបាញ់ចោល ។

ប៊ុនថន: ខាងណាវិញ?

ងើត: ខាងទាហានហេង សំរិនហ្នឹង ទាហានសព្វថ្ងៃនេះណាស់ ។

ប៊ុនថន: បាទ ។

ងើត: ទាហានខាងក្នុងហ្នឹង គេបញ្ជាឲ្យមកចាប់តា ពិនយកទៅបាញ់ចោល ។

ប៊ុនថន: កាលហ្នឹងឆ្នាំណាហើយ?

ងើត: មិនដឹងជាឆ្នាំណាទេ វា៩០លើសមកហើយ ។

ប៊ុនថន: កាលហ្នឹង៩៣ឬមួយក្រោយទៀតអី?

ងើត: ក្រោយទៀត ក្រោយ៩៣ហើយ ។

ប៊ុនថន: គាត់គ្រោះថ្នាក់ហើយកាលហ្នឹង?

ងើត: ហាស់ ។

ប៊ុនថន: គាត់គ្រោះថ្នាក់ដោយសារចោរប្លន់គាត់ហើយនៅកាលហ្នឹង?

ងើត: នៅ អាចោរប្លន់ឆ្នាំ៩៦ ។

ប៊ុនថន: មុនចោរប្លន់អី?

ងៀត: ក្រោយ ។

ប៊ុនថន: ក្រោយចោរប្ញូន?

ងៀត: ហ្នឹងហើយ ក្រោយចោរប្ញូនទៅបាននេះ៩៧នេះឯងតាមមើលមិនយូរទេ ខ្ញុំចាំវាមិនបានទៅណាស់ ។

ប៊ុនថន: បាទ ។

ងៀត: ទៅដល់គាត់ណៃ ដល់នេះទៅគេបញ្ជាមកឲ្យចាប់គាត់ខ្ញុំទៅធានាម្តងទៀត ធានាទៅក៏បានរួចរួចទៅខ្ញុំថា អាភ័ណ្ឌកូនក្មួយខ្ញុំហ្នឹងវាធ្វើនាយក ហើយក៏ឲ្យទៅនៅស្រុក ដល់ទៅនៅស្រុកស្វាយចេកនោះនៅធ្វើការនៅស្វាយចេកនោះ ធ្វើនៅស្វាយចេកបានប៉ុន្មានទេ ប្រហែលជាមួយឆ្នាំឬពីឆ្នាំទេ បានគេមានផែនការមកពីក្នុងនោះថ្នាក់លើថាមកចាប់តា ពិនខ្ញុំក៏អត់ដឹងដែរ ខ្ញុំនៅតែនេះមានអីមិនដឹង បន្តិចគេប្រាប់មកព្រោះក្មួយខ្ញុំវាបង្រៀននៅនោះដែរ ថាតា ពិនគេចាប់ហើយ ដឹងថាតា ពិនធ្វើអីៗដឹងនៅពេលគេចាប់ហ្នឹងហើយ ។

ប៊ុនថន: ចឹងពីមុនមកមិនបានដឹងទេ?

ងៀត: ខ្ញុំមិនបានដឹងអីទេ បើដឹងស្លាប់ហើយពីណាទៅហ៊ានធានាមនុស្សចុះនោះ ម៉ាហ៊ឺកនោះគេចង់បាញ់ចោលយូរណាស់ហើយ ។

ប៊ុនថន: ចឹងកាលហ្នឹងយ៉ាងម៉េចបានជាគេចាប់គាត់ អឹមានដឹងថាម៉េចបានគេចាប់គាត់?

ងៀត: អត់មានដឹងទេ បើដឹងចុះស្លាប់ហើយខ្ញុំដែលហ៊ានធានា ។

ប៊ុនថន: បាទ ។

ងៀត: ធានាបានរួចមួយវគ្គទៅ ។

ប៊ុនថន: ចឹងគាត់មកដល់ដំបូងហ្នឹងគាត់មានដែលនិយាយលេងពីប្រវត្តិគាត់ពីមុនអីទេ?

ងៀត: គាត់មិនដែលនិយាយពីការធ្វើខ្មែរក្រហមមិនដែលនិយាយទេ ។

ប៊ុនថន: ពីប្រវត្តិថាបង្រៀនមិញ?

ងៀត: បើបង្រៀនគាត់បង្រៀនផ្នែកគ្រូសាស្ត្រាចារ្យប៉ុណ្ណោះឯង គាត់និយាយតែពីសង្គមណាស់ ។

ប៊ុនថន: បាទ ។

ងៀត: ដល់សម័យបីឆ្នាំនេះគាត់មិនដែលនិយាយទេ បើគាត់និយាយថាទៅរៀននៅស្រុកចិនមានប្រាក់គាត់រៀននៅស្រុកចិនណាស់ ។

ប៊ុនថន: គាត់ទៅបង្រៀនឬទៅរៀន?

ងៀត: គាត់ទៅរៀន ទៅរៀននៅស្រុកចិនដែលគេសម័យខ្មែរក្រហមនេះណាស់ ។

ប៊ុនថន:	បាទ ។

ង៉ែត:	គេឲ្យទៅរៀនស្រុកចិន មិនដឹងជារៀនប៉ុន្មានឆ្នាំទេ គាត់មិនដែលប្រាប់អស់ដឹងថាពីរឿងទៅរៀនប៉ុណ្ណោះ ។

ប៊ុនថន:	ក្រៅពីនិយាយរឿងហ្នឹងមានគាត់មាននិយាយលេងរឿងផ្សេងៗទេ?

ង៉ែត:	អត់ទេ មាននិយាយអីទេ គាត់ជាមនុសសរៀងស៊ុៗចឹងផង គាត់លាក់ចំណេះណាស់មនុស្សហ្នឹង ខ្ញុំគាត់លួចបើកថា សម័យពីសង្គមមិញគាត់ធ្វើគ្រូសាស្រ្តាចារ្យផុតពីនោះមិនដែលមានពីណាដឹងទេ ។

ប៊ុនថន:	បាទ ។

ង៉ែត:	ដល់ចូលសម័យខ្មែរក្រហមគាត់មិនប្រាប់ទេ ធ្វើអីៗធំដុំដល់ដឹងមកក្រោយនេះគាត់ធ្វើធំចឹងឥឡូវមិនដែកហ៊ានបៀតទេ ។

ប៊ុនថន:	បាទ ។

ង៉ែត:	តែមើលទៅមុខគាត់រៀងកាច ។

ប៊ុនថន:	តែគាត់មិនដែលមានទាស់ជាមួយអកភូមិអីទេ?

ង៉ែត:	អត់ទេ មិនដែលមានទាស់អីទេ មានទាស់ទាល់តែអ្នកភូមិចូលដៃជាមួយទាហានខាងក្នុងផងទាស់តែរឿងមាសហ្នឹងអ្នកប្ងន់និងមានចូលអ្នកភូមិផង ចូលខ្លះដឹងថាតាហ្នឹងមានមាសច្រើនមាសពីរកំប៉ុង ។

ប៊ុនថន:	បាទ!តែតា ពិតគាត់មានមាសអីទេ ប្លន់បានមាសទេ?

ង៉ែត:	ទេ មានបានទេ បើតាមមាសមុនដំបូងគាត់យកទៅផ្ញើរនិងយាយខ្ញុំហ្នឹងឯង ផ្ញើរយាយខ្ញុំមាសកូនស្រីមួយនោះមួយខែ ផុតនោះមាននាឡិកាយើងនាឡិកាមកពីស្រុកចិនឲ្យកូនម្នាក់មួយៗដល់ស្រុកស្រួលយកមកឲ្យទុកវិញទៅ កាលគេប្លន់មិនដឹងបានអានោះមិនបានអីទេនាឡិកាម៉ាកអីទេលក់បានរាប់ម៉ឺននិងគេណា កាលនោះលក់បានមួយម៉ឺនជាងអីកាលនោះលក់បានមួយម៉ឺន ។

ប៊ុនថន:	កាលគាត់មកហ្នឹងមានកូនប៉ុន្មាននាក់អ៊ំ?

ង៉ែត:	កូនបីនាក់ ។

ប៊ុនថន:	ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ង៉ែត:	អូស!កូនបួនតើ ប្រុសមួយស្រីបី ។

ប៊ុនថន:	បាទ ។

ង៉ែតៈ ក្មេចឈ្មោះអស់ទៅណាស់ បែកយូរពេកក្មេចឈ្មោះទៅ ។

ប៊ុនថនៈ ចឹងដិបូងគាត់មកនេះរកស៊ីអីដែរ?

ង៉ែតៈ មកនេះនោះដូចខ្ញុំថា ខ្មែរក្រហមមានក្រុមហ៊ុនម៉ាស៊ីនកិនស្រូវ កិនស្រូវៗមិនដឹងជាយ៉ាង ម៉េចស្រុកគេរៀងស្រួលទៅគេដកម៉ាស៊ីនកិនចេញគាត់នៅរកស៊ីធម្មតា ធ្វើស្រែធ្វើអីទិញ ស្រែទៅណាស់ ទិញគោគាត់ឃ្វាលគោមើលធ្វើស្រែហ្នឹងគេទៅមួយឆ្នាំឈប់ទៅមកទិញ ឥវ៉ាន់លក់ ឈប់ធ្វើស្រែមកទិញឥវ៉ាន់លក់ដូរទៅ លក់ចាប់ហួយបន្តិចបន្តួចទៅណាស់ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ រួចគាត់ធ្វើគ្រូបង្រៀនទៀតទៅជុំគ្នាហ្នឹងហើយ ចប់ពេលដែលគេចាប់ទៅស្វាយចេកដែលខ្ញុំ ប្រាប់ណាស់ ទៅដល់ស្វាយចេកទៅគេចាប់នៅស្វាយចេកចាប់បាត់គ្នាត្រឹមនោះទៅ កូន គាត់រប៉ាត់រប៉ាយមិនដឹងជាទៅនៅណាខ្លះទេ ។

ប៊ុនថនៈ អត់មានដឹងអត់មានដែលមកលេងទេ?

ង៉ែតៈ អត់ទេ មួយស្រីនោះឮថាទៅនៅកំពង់ធំប្រុសនេះមិនដឹងជានៅណាទេ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ កូនតូចមួយនៅជាប់ប៉ុនអានេះ កូនតា ពិន ដល់គេចាប់ទៅមិនដឹងជានៅណាទេ ។

ប៊ុនថនៈ ដែលខស្សាហ៍ទៅលេងជិនុំគ្នាដែលកាលគាត់នៅអីចឹង?

ង៉ែតៈ ទេ ។

ប៊ុនថនៈ និយាយថារាប់អានដូចអ្នកភូមិធម្មតាចឹង?

ង៉ែតៈ បាទ!និយាយរាប់អានគ្នាធម្មតាទៅមាននិយាយអីពីរឿងនយោបាយស្អីមិនដែលនិយាយទេ កាលហ្នឹង ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ គាត់ធ្វើរបស់គាត់នៅ ខ្ញុំកាលហ្នឹងខ្ញុំថា តា មិនទៅស្រុកវិញទៅខ្ញុំដឹងរឿងថាគេប្រុសចាប់ មួង ខ្ញុំថាបើចេះហើយទៅស្រុកវិញទៅ គាត់ថាមិនហ៊ានទៅទេ ។

ប៊ុនថនៈ គាត់ថាចឹង?

ង៉ែតៈ ហ្នឹងហើយ គាត់ថាមិនហ៊ានទៅទេ ថាស៊ូគាត់នៅនេះគាត់ថាចឹងណាស់ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ គាត់ប្រហែលជាមានអីម៉្យាងៗហើយប្រហែលខ្ញុំគ្រាន់តែគិតខ្លួនខ្ញុំ ។

ប៊ុនថនៈ បាទ ។

ង៉ែត: ដល់ពេលគេចាប់ចេះបានដឹង ចឹងថាបានមិនហ៊ានទៅស្រុក ។

ប៊ុនថន: បាទ ។

ង៉ែត: ខ្ញុំដេញឲ្យទៅស្រុកទាំងប្រពន្ធទាំងអីហ្នឹង នៅទាល់តែស្លាប់ ។

ប៊ុនថន: ចឹងអ៊ីធ្លាប់និយាយប្រាប់ដែរ?

ង៉ែត: ប្រាប់ ។

ប៊ុនថន: តែដឹងថាស្រុកគាត់នៅណាដែលកាលហ្នឹង?

ង៉ែត: ថានៅកំពង់ឆ្នាំង ។

ប៊ុនថន: កំពង់ឆ្នាំ?

ង៉ែត: បាទ!ស្រុកប្រពន្ធដឹង ។

ប៊ុនថន: បាទ!ចឹងដល់ពេលចាប់ហើយបានអ៊ីដឹង?

ង៉ែត: ដឹងគេនិយាយចេះចុះទៅបានដឹងគេផ្សាយតាមវិទ្យុ ខ្ញុំគេហៅទៅតុលាការម្ដង កាលនោះដែលគេបាញ់តា ពិនណាស់ ។

ប៊ុនថន: បាទ ។

ង៉ែត: គេបាញ់ តា ពិនប្រពន្ធតា ពិនស្លាប់ទៅខ្ញុំមានបានដឹងអី ខ្ញុំឆ្នាំដែលគេបាញ់ហ្នឹងខ្ញុំទៅវះពោះយកគ្រាប់ខ្ទនចេញនៅមន្ទីលបូរី ។

ប៊ុនថន: បាទ ។

ង៉ែត: ខ្ញុំមិនដឹងឆ្លើយថាម៉េច ខ្ញុំឆ្លើយថាខ្ញុំមិនដឹងចប់ ។

ប៊ុនថន: បាទ ។

ង៉ែត: ខ្ញុំមិនបានដឹងរឿងគេ មិនដឹងជាបួន់រឿងអី ។

ប៊ុនថន: ចឹងអ្នកភូមិទាំងអស់គាត់មិនដឹងថាពីមុនគាត់ធ្វើអីដែរ?

ង៉ែត: អត់ទេ មិនបានដឹងទេ ។

ប៊ុនថន: បាទ ។

ង៉ែត: បើទាហានគ្នាគេដែលមានមកពីនោះមិនដឹង អ្នកភូមិផ្ដាំមិនដឹងទេ គាត់នោះមកពីនិរតីមកណាទេ រត់ទៅនៅជំរំនេះតែម្ដង ។

ប៊ុនថន: អ៊ីមានបានទៅជំរំអីទេអ៊ី?

ង៉ែត: ជំរំខ្មែរក្រហមហ្នឹង?

ប៊ុនថន: បាទ!ជំរំគេរត់ទៅហ្នឹងអ៊ី?

ងែត: មានជំរំប៉ាភមានជំរំខ្មែរក្រហម ។

ប៊ុនថន: បាទ!មានបានទៅទេអ៊ី?

ងែត: ខ្មែរក្រហមខ្ញុំអត់ទៅទេ បើជំរំប៉ាភខ្ញុំទៅជំរំសាយធូ ។

ប៊ុនថន: សាយធូ?

ងែត: ខ្ញុំទៅលេង ទៅលេងម៉ែក្មេងខ្ញុំនៅនោះក៏ទៅ ទៅលេងតស៊ូណាស់ខ្ញុំទៅនៅក្រាប់រំសេវបាញ់ផ្ទោងអាសែសិបការុន ខ្ញុំតស៊ូនៅតែផ្ទះ បាញ់ដាក់ភូមិចេះនៅតែផ្ទះចឹងឯងក្រាបគ្រន់សេតែចុះឯង ។

ប៊ុនថន: បាទ ។

ងែត: តស៊ូណាស់ខ្ញុំ ។

ប៊ុនថន: គ្រួសារអ៊ីនៅស្រុកណាដែលអ៊ី?

ងែត: នៅភូមិថ្កាំហ្នឹង យាយខ្ញុំថ្ងៃនោះគាត់សម្ភាសន៍ផង អត់មានពីណាសម្ភាសន៍ចូលសម្ភាសន៍យាយខ្ញុំ ។

ប៊ុនថន: ចឹងរាល់ថ្ងៃនេះខស្យាហ៍ទៅថៃដែរ?

ងែត: ខ្ញុំនោះ ។

ប៊ុនថន: បាទ ។

ងែត: ខ្ញុំមិនដែលបានទៅថៃទេ មិនដែលបានទៅណានៅតែផ្ទះកូនធ្វើផ្ទះនេះទៅ កូនទី២វាធ្វើផ្ទះចំពាក់គេក៏មកនៅចាំ ចាំមួយឆ្នាំជាងហើយនេះ វាមកវិញហើយវាមកបានប៉ុន្មានថ្ងៃហើយឥឡូវនេះ ។

ប៊ុនថន: ចឹងអ៊ីផ្ទះនៅណាចឹង?

ងែត: ផ្ទះខ្ញុំនៅនោះភូមិធំ ។

ប៊ុនថន: បាទ!អ៊ីមកនេះមកចាំផ្ទះឲ្យកូន?

ងែត: បាទ!នៅចាំផ្ទះក៏ដល់មកបានតែម៉ារួចចមពាក់គេ ដល់ធ្វើទៀតមិនមានជញ្ជាំងដាក់ទេមើលអាជញ្ជាំងក្រោមមិនមានអាជញ្ជាំងលើក៏មិនមានចំហធុង ថាទៅតស៊ូនៅថៃមួយខែពីរខែទៀតក្រែងបានទិញខោអាវមកស្នៀកពាក់ឲ្យវា ។

ប៊ុនថន: បាទ!អ៊ីមានកូនប៉ុន្មាននាក់?

ងែត: កូនបង្កើតមាន៦នាក់ ។

ប៊ុនថន: មានគ្រួសារអស់ហើយអ៊ី?

ង៉ែត: មានអស់ហើយ អាចុងគេនោះក៏មានគ្រួសារអស់ អានោះធ្វើគ្រូបង្រៀនជាប់រាល់ថ្ងៃ។

ប៊ុនថន: ចឹងអ៊ំមានដែលទទួលដំណឹងពីការកាត់ទោសឌុចអីទេអ៊ំ?

ង៉ែត: ខ្ញុំដឹងតែតាមវិទ្យុនិងតាមទូរទស្សន៍ហ្នឹង។

ប៊ុនថន: បាទ។

ង៉ែត: ឲ្យតែថ្ងៃណាគេកាត់ទោសគា ពិនអីទៅមើល។

ប៊ុនថន: ចឹងបើនៅរាល់ថ្ងៃហ្នឹងគាត់ស្គាល់អ៊ំដែរ?

ង៉ែត: ស្គាល់នៅសប្ដថ្ងៃបើឃើញខ្ញុំស្គាល់ មិនស្គាល់យ៉ាងម៉េចបើមនុស្សនៅជិតគ្នាហ្នឹងនៅផ្ទះអែបគ្នា គាត់នៅជើងចឹង នៅប្រហែលដើមត្នោតចុះឯង។

ប៊ុនថន: បាទ។

ង៉ែត: គាត់មកលេងផ្ទះខ្ញុំ។

ប៊ុនថន: ចឹងគេកាត់ទោសគាត់១៨ឆ្នាំ ខាងតុលាការឲ្យគាត់ជាប់ទោស១៨ឆ្នាំ បើសិនជាអ៊ំ អ៊ំយល់យ៉ាងម៉េចដែរ១៨ឆ្នាំប្ដមួយតិចប្ដច្រើនអីសម្រាប់គាត់?

ង៉ែត: ខ្ញុំមិនដឹងជានិយាយថាម៉េចទេ ១៨ឆ្នាំវាអស់ហើយគាត់អាយុ៦៨ហើយដឹង។

ប៊ុនថន: បាទ។

ង៉ែត: ៦៨ហើយកាត់ប៉ុណ្ណោះវាស្លាប់តែដដែលណា ដាក់ទោសទក្រិដ្ឋប៉ុណ្ណោះ។

ប៊ុនថន: បាទ។

ង៉ែត: មួយជីវិត។

ប៊ុនថន: អ៊ំមានអីចង់និយាយថែមទេអ៊ំ មានអ្វីដែលចងចាំហើយសំខាន់ចឹង?

ង៉ែត: ខ្ញុំដល់គាត់ចុះខ្ញុំមិនដឹងទេ ខ្ញុំតែនិយាយទៅចងចាំកំហឹង កំហឹងនិយាយតែពីប៉ុល ពត ត្រង់គាត់មិនដែលបានមកធ្វើបាបខ្ញុំ ខ្ញុំមិនបានថាអី។

ប៊ុនថន: បាទ។

ង៉ែត: បើខឹង ខឹងតែនោះទេ វាធ្វើបាបសម័យនោះ សម័យបីឆ្នាំប្រាំបីខែម្ភៃថ្ងៃ។

ប៊ុនថន: បាទ។

ង៉ែត: អាហ្នឹងវាមានពិតមែនហើយសម័យនោះវាខ្លាំងចឹងមែនធ្វើបាបប្រជាជន តែខ្ញុំសម័យនោះបងប្អូនខ្ញុំអត់មានគ្រោះថ្នាក់អីទេ?

ប៊ុនថន: បាទ!អត់មានស្លាប់?

ង៉ែតៈ អត់ទេ អត់មាន អត់មានគ្រោះថ្នាក់និងគេទេ កាលគេយកទៅវ៉ៃចោលទាំងហ្វូងៗនោះក៏មិនប៉ះ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ ចេះតែផុតទៅវានិយាយទៅម៉ាបងប្អូនខ្ញុំនិយាយថាជាមនុស្សអ្នកធ្វើចេះគិតច្រើនទៅមិនធ្វើអំពើហឹង្សាទៅ ចេះតែខ្លាចគេទៅណាស់ ។

ប៊ុនថនៈ បាទ ។

ង៉ែតៈ បានវារស់យើងទៅធ្វើខុសដាក់គេ គេវ៉ៃចោល ។

ប៊ុនថនៈ បាទ!ចឹងខ្ញុំដូចជាអត់មានអីសួរអីថែមទៀតទេ អរគុណអ៊ំច្រើន ។

ង៉ែតៈ បាទ ។

«ចប់»